# "សិប្បកម្មខ្មែរ" ផលិតវត្ថុប្រើប្រាស់ប្រកបដោយសិល្បៈ

សិប្បកម្ម គឺជាផ្នែកមួយយ៉ាងសំខាន់នៃអត្តសញ្ញាណវប្បធម៌។ ក្នុងសង្គមខ្មែរ គេសម្គាល់ឃើញវត្ថុផ្សេងៗដែលកើតពីការងារសិប្បកម្ម តែងរំលេចនូវទឹកដៃសិល្បៈយ៉ាងល្អវិសេស បន្ថែមលើមុខងារប្រើប្រាស់នៃវត្ថុនោះផង។ កិច្ចការសិប្បកម្មនេះគេមើលឃើញថាហាក់ដូចជាបានដក់ជាប់ក្នុងចិត្តគំនិតដូនតាមកឥតដាច់ ដ្បិតតាមរយៈពាក្យទូន្មានប្រៀនប្រដៅ កំណាព្យ ចម្រៀង ឬគំនូរ ច្រើនតែលើកយកទិដ្ឋភាពនៃការត្បាញហូល ធ្វើទូក ធ្វើទេះ វេញខ្សែ ដំដែក ធ្វើទ្រូ លប លាយ ឬឧបករណ៍ភ្លេងជាដើម។ ចំណេះជំនាញទាំងអស់នេះតែងផ្ទេរបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត ហើយមានចែងពីការយកចិត្តទុកដាក់ផ្ដល់តម្លៃជាសកលក្នុងអនុសញ្ញាឆ្នាំ២០០៣ នៃអង្គការយូណេស្កូ ស្ដីពី "ការការពារមត៌កវប្បធម៌អរូបី"។[1]

ជាការពិត "សិប្បកម្ម" មានន័យទូលំទូលាយក្រៃលែង ពោលគឺជាការងារធ្វើដោយដៃ ឬវត្ថុជាហត្ថកម្ម កើតឡើងពីចំណេះជំនាញប្រកបដោយសិល្បៈ ហើយជាវិជ្ជាដែលភាគច្រើនចេះមកពីការស្វែងយល់ សង្កេត បង្រៀន និងរៀនអនុវត្តបន្តពីជំនាន់មួយទៅជំនាន់មួយទៀត (រូបលេខ១)។ វត្ថុផ្សេងៗដែលកើតពីសិប្បកម្មមានដូចជា ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ(កាំបិត, ពូថៅ, ល្អី, កញ្ច្រែង...), នេសាទោបករណ៍ (ឈ្នាង, ទ្រូ, អង្រុត...), ឧបករណ៍តម្បាញ (ត្រល់, កី, រហាត់, ធ្មេញឈើ...), ឧបករណ៍ភ្លេង (ទ្រ, ចាប៉ី, ឃឹម, ស្គរ, រនាត...), គ្រឿងដឹកជញ្ជូន (រទេះគោ, រទេះសេះ, ទូក...), ព្រមទាំងគ្រឿងល្ខោន ឬរបាំ (ស្បែកល្ខោន, មុខខ្នុក...) ជាដើម (រូបលេខ២-៣)។ ដោយមើលឃើញពីគុណតម្លៃ និងបញ្ហាប្រឈមក្នុងសម័យសកលភាវូបនីយកម្មនេះ រាជរដ្ឋាភិបាលចាត់ទុកការងារសិប្បកម្មជា "វិជ្ជាជីវៈដូនតា" ឬ "ជំនាញដូនតា" ត្រូវគិតគូរលើកតម្លៃជាបន្តបន្ទាប់ តាមរយៈយន្តការនៃការបណ្ដុះបណ្ដាលយុវជននៅតាមគ្រឹះស្ថានអប់រំរបស់រដ្ឋ។ ខាងក្រោមនេះ ជាការសង្កេតយ៉ាងសង្ខេបអំពីសិប្បកម្មខ្មែរខ្លះៗ ដែលធ្លាប់ឃើញទាំងក្នុងឯកសារ និងកំពុងបន្តអនុវត្តជាប្រក្រតី។

---

[1] សូមអានបន្ថែម៖ អនុសញ្ញាអង្គការយូណេស្កូ ឆ្នាំ២០០៣ ស្ដីពីការការពារមត៌កវប្បធម៌អរូបី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើពិនិត្យឃ្លាខ្លះនៅក្នុងច្បាប់ស្រី ដែលអ្នកខ្លះយល់ថាសរសេរក្នុងសតវត្សទី១៩ មានឃ្លាមួយយ៉ាងសំខាន់លើកឡើងទូន្មានមនុស្សស្រី ឱ្យយកចិត្តទុកដាក់ក្នុងកិច្ចការត្បាញរវៃថា "[...] ធ្វើការផងណាប្រើខំ ទោះត្បាញចាក់ដំ នាងខំឱ្យហើយ។ កុំទុកទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណា។ ទោះធ្វើហូលគោមប្រែផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ។ ធ្វើឱ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឱ្យដើរ លេងផ្ទះគេណា [...]"[2] ចំណែកឯក្នុងច្បាប់ល្បើកថ្មី ដែលគេស្គាល់ជាទូទៅថាជាស្នាដៃរបស់លោកតា ក្រមង៉ុយ ក៏រំលេចកិច្ចការសិប្បកម្មទាំងនោះថា "[...] ឱ្យសួរចាស់ៗ រៀនបេះកប្បាស ថ្លៃចម្ងូរសំឡី រៀនកូតរៀនការ ត្រសាវពាត់រវៃ ហូលគោមគាតក្តី កុំបីចន្លោះ។ រៀនថ្កររៀនត្បាញ ឱ្យចាស់បង្ហាញ បង្ហាត់ឱ្យអស់ សំពត់បែបផ្កាយ លាយសូត្រអំបោះ កុំទិញគេសោះ ឈ្មោះការជាស្រី។ ទិញដូរតែលក្ខ អញ្ចុលចេសចាក់ ព្រហូតជាបី ធ្មេញឈើឈ្នាន់ផ្សំ ក្តារម្ងូរក្តារកី ត្រល់ខ្នារឫស្សី មុខប្តីជាប្រុស [...]"[3] ផ្អែកតាមសេចក្តីរៀបរាប់នេះ គេមើលឃើញថា សង្គមខ្មែរតែងពឹងអាស្រ័យកិច្ចការសិប្បកម្មជាធំ ហើយស្ត្រីគឺជាមនុស្សសំខាន់ក្នុងការងារទាំងនោះ ជាពិសេស គឺការត្បាញរវៃ (រូបលេខ៤-៦)។

ដោយឡែក ក្រៅពីមានរៀបរាប់ក្នុងច្បាប់ក្បួនទូន្មានបែបបុរាណខាងលើនេះ នៅក្នុងគំនូរតាមវត្តខ្លះ ក៏មានរំលេចទិដ្ឋភាពការងារសិប្បកម្មផងដែរ។ ជាក់ស្តែង គេឃើញមានគំនូរមួយផ្ទាំងនៅវត្តកំពង់ត្រឡាចលើ បង្ហាញទិដ្ឋភាពជាងដែក ជាងដេរ និងសកម្មភាពការងារសិប្បកម្មផ្សេងទៀតកំពុងប្រព្រឹត្តជាប្រក្រតី នៅត្រង់ផ្ទាំងដែលនិយាយពីនាងអមិត្តតាបនា និងតាជូជក ដើរកាត់ផ្សារ (រូបលេខ៧)។ ទិដ្ឋភាពក្នុងនេះក៏ស្តែងឱ្យឃើញពីស្រុកភូមិមួយចំនួនដែលនៅមានរបរសិប្បកម្មផ្សេងៗ ជាពិសេសគឺរបរជាងដែក តែងសម្គាល់ឃើញមានជាហូរហែ ដ្បិតកសិករត្រូវការកាំបិត ពូថៅ ជ្រនីក... សម្រាប់ប្រើប្រាស់ក្នុងរបរធ្វើស្រែចម្ការ។[4] លើសពីនេះ ចំពោះការងារតម្បាញក្នុងសង្គមខ្មែរទៀតសោត គេតែងសង្កេតឃើញមានតាំងពីបុរាណមក រហូតដក់ជាប់ជាសេចក្តីទូន្មានពាក់ព័ន្ធនឹង

---

[2] សូមអាន៖ "ច្បាប់ស្រី" ដោយ ហ៊ឹន ម៉ៃ ១៩៥៧

[3] ពុទ្ធសាសនបណ្ឌិត្យ ១៩៧២: ២៧-២៨

[4] ជុំ សុវណ្ណមាលា ២០១៣-២០១៤: ២-៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

កិច្ចការនេះជាច្រើននៅក្នុងច្បាប់ផ្សេងៗ។ មិនតែប៉ុណ្ណោះ សម្ភារៈតម្បាញទាំងអស់ដែល គេតែងឃើញថា សុទ្ធសឹងជាវត្ថុមានក្បាច់រចនាដោយទឹកដៃសិល្បៈយ៉ាងល្អប្លែក ដូចមាន សម្ភារៈខ្លះដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរជាតិភ្នំពេញភ្នំពេញជាភស្តុតាងស្រាប់ (រូបលេខ៨-១០)។

សង្ខេបសេចក្តីមក សិប្បកម្មក្នុងសង្គមខ្មែរមានច្រើនទម្រង់រាប់មិនអស់។ វត្ថុប្រើប្រាស់នីមួយៗដែលកើតចេញពីសិប្បកម្មខ្មែរ តែងសម្គាល់ឃើញភ្ជាប់ដោយគំនិតសិល្បៈ ឬក្បាច់រចនាលម្អគួរឱ្យកោតសរសើរ។ ប៉ុន្តែស្ថិតក្នុងសម័យសាកលភាវូបនីយកម្មនេះ វត្ថុសិប្បកម្មខ្លះត្រូវជំនួសដោយទំនិញនាំចូល ស្របពេលដែលតាមសហគមន៍មួយចំនួនប្រឈមនឹងកង្វះអ្នកបន្តវេន និងទីផ្សារ ដែលជាហេតុបណ្តាលឱ្យវិស័យសិប្បកម្មបុរាណកាន់តែថមថយ៕

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

## បញ្ជីរូបភាព



រូបលេខ១ ការសង្កេតរបស់ក្មេងជំនាន់ក្រោយចំពោះការងារសិប្បកម្ម



រូបលេខ២ សិប្បកម្មផលិតឧបករណ៍ភ្លេង



រូបលេខ៣ សម្ភារៈប្រើប្រាស់ត្បាញពីរពាក់

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៤ ស្ត្រីអង្គុយត្បាញនៅទសវត្សរ៍១៩៣១ (រូបថត៖ Leon Bussy)



រូបលេខ២៥ ស្ត្រីត្បាញហូលនៅស្រុកបាទី ខេត្តតាកែវ (រូបថត B. Dupaigne, 1968)



រូបលេខ២៦ ស្ត្រីបេះកប្បាស (រូប៖ ព្រឹត្តបត្រ Le Cambodge)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៧ គំនូរវត្តកំពង់ត្រឡាចលើ បង្ហាញទិដ្ឋភាពផ្សារដែលមានរបរសិប្បកម្មផ្សេងៗ




រូបលេខ២៨ សម្ភារៈតម្បាញតាំងនៅសារមន្ទីរជាតិភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ជុំ សុវណ្ណមាលា

*២០១៣-២០១៤*, "ដាងដែក", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២៩*, ទំ.២-៧, Friends of Khmer Culture, ភ្នំពេញ

ហ៊ីន ម៉ែ

(?) *ច្បាប់ស្រី*, បណ្ណាគារ តិច ហុង (បោះពុម្ពឆ្នាំ១៩៥៧), ភ្នំពេញ

អ៊ុក អ៊ូ (ក្រម ង៉ុយ)

*១៩៧២*, *ច្បាប់ល្បើកថ្មី*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION